ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១២៤៩/២២-១០-២០១៨

សាលដីកា
លេខ ១១៨ ក្រវន
ចុះថ្ងៃទី០២-១២-២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពី ការរៀបចំអង្គការតុលាការដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

ឆ្នាំពីរពាន់ម្ភៃមួយ ខែវិច្ឆិកា ថ្ងៃទីបី វេលាម៉ោង ប្រាំបី នាទីព្រឹក សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ បានបើកសវនាការជាសាធារណៈ ដែលមានសមាសភាពដូចខាងក្រោម៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា
ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងសភាព្រហ្មទណ្ឌលេខ ១២៤៩ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ លើជនជាប់ចោទដែលមានដូចខាងក្រោម៖

ជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ស្នា ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ទីលំនៅសព្វ[redacted] ភូមិទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង នៅលីវ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន។ (ក្រៅឃុំ)

ជាប់ចោទពីបទ៖ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តចំណុចផ្ទះ[redacted] សង្កាត់ទួលឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ចិន្តា ភេទស្រី អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ[redacted] ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

-លោក [redacted] សុខា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ឈ្មោះ [redacted] ចិន្តា ភេទស្រី បានធ្វើដំណើរពីភ្នំពេញមកបាត់ដំបងវេលាម៉ោងមួយរំលងអាធ្រាត ហើយក៏បានពឹងឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ ២៥ឆ្នាំ ឲ្យជូនទៅផ្ទះ





Scanned with CamScanner

ប៉ុន្តែឈ្មោះ [redacted]វាសនា បដិសេធថាមិនជូនទៅផ្ទះទេ ព្រោះយប់ជ្រៅហើយក៏បានលួងជនរងគ្រោះឈ្មោះ [redacted]ចិន្តា ឲ្យទៅសម្រាកនៅផ្ទ[redacted] ភូមិអូរតាគាំ១ សង្កាត់ទួលតាឯក ក្រុង-ខេត្តបាត់ដំបង មួយយប់សិនចាំព្រឹកឡើងជូនទៅផ្ទះ។ លុះពេលទៅដល់ក្នុងបន្ទប់ផ្ទះសំណាក់ឈ្មោះ [redacted] វាសនា បានចាក់សោរ និងចាក់គន្លឹះទ្វារជាប់ ហើយក៏ច្រានជនរងគ្រោះឲ្យដួលទៅលើគ្រែ រួចបានខ្ទប់មាត់ជនរងគ្រោះមិនឲ្យស្រែក ហើយក៏បានចាប់រំលោភជនរងគ្រោះរហូតដល់បានសម្រេច ខណៈពេលធ្វើសកម្មភាពឈ្មោះ [redacted] វាសនា ភេទប្រុស បានគម្រាមជនរងគ្រោះមិនឲ្យស្រែក បើហ៊ានស្រែកនឹងច្របាច់កសម្លាប់ចោលភ្លាម។

**បានឃើញ** សាលក្រមព្រហ្មទណ្ឌ លេខ ៤៦១ "ឃ" ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចខាងក្រោម៖

១.ផ្តន្ទាទោសលើឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ (សាវតាជាតិគ្រប់គ្រាន់ខាងលើ) ដាក់ពន្ធនាគារកំណត់ ៥ (ប្រាំ) ឆ្នាំ ពីបទ រំលោភសេពសន្ថវៈ តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តចំ[redacted] សង្កាត់ទួលឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៦។

២.ឲ្យឈ្មោះ [redacted]វាសនា សងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ចិន្តា ការទាមទារលើសពីនេះច្រានចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**បានឃើញ** សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៤៨ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ[redacted] តារា ជាមេធាវីការពារជនជាប់ចោទឈ្មោះ[redacted]វាសនា សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមលក្រមព្រហ្មទណ្ឌ លេខ ៤៦១ "ឃ" ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**បានឃើញ** របាយការណ៍របស់សាលាឧទ្ធរណ៍ភ្នំពេញ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩។

**បានឃើញ** សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១។

## នាពេលសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ អានរបាយការណ៍ក្នុងសំណុំរឿង។

-ជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ស្នា បានឆ្លើយថា បានជាខ្លួនប្តឹងឧទ្ធរណ៍មកនេះដោយមិនមានភស្តុតាងត្រឹមត្រូវ ហើយមិនស្របតាមល័ក្ខខ័ណ្ឌ កាលដែលខ្លួនជូនគាត់ទៅផ្ទះសំណាក់ក៏គាត់ជាអ្នកសុំខ្លួនឲ្យជូនទៅដែរ បានជាខ្លួនជូនគាត់ទៅផ្ទះសំណាក់ ពីព្រោះគាត់មកពីភ្នំពេញដល់បាត់ដំបងនៅម៉ោងប្រហែលជា ១២ ទៅ ១ យប់ រួចហើយគាត់បានតេទូរសព្ទហៅខ្លួនឲ្យមកជូនគាត់ទៅផ្ទះ ហើយគាត់មិនបានហៅអ្នកផ្ទះគាត់មកយកគាត់ទៅផ្ទះទេ ហើយនៅពេលដែលគាត់មកដល់បាត់ដំបងគាត់ក៏មិនបានទៅផ្ទះទេ ហើយគាត់ថាយប់ហើយ ពេលនោះគាត់ថាមិនបានប្រាប់ទៅអ្នកផ្ទះបានដឹងដែរ ពេលនោះគាត់ប្រាប់ថានៅដេកផ្ទះសំណាក់មួយយប់សិនចាំស្អែកព្រឹកចាំទៅផ្ទះ ហើយខ្លួនក៏បានជួយយកឥវ៉ាន់គាត់ជូនទៅផ្ទះសំណាក់



Scanned with CamScanner

ទៅ ហើយពេលដែលខ្លួនជូនគាត់ដល់ផ្ទះសំណាក់រួចខ្លួនក៏បានចេញទៅផ្ទះវិញ ពេលដល់បន្ទប់ផ្ទះសំណាក់នោះខ្លួនមិនបានដេកនៅទីនោះជាមួយគាត់ទេ ហើយក៏មិនបានចាប់រំលោភគាត់ដែរ ហើយម៉ោង ៤ ជិតភ្លឺខ្លួនក៏មកយកគាត់ជូនទៅផ្ទះវិញ នៅពេលទៅយកគាត់ខ្លួនមិនបានចាប់រំលោភគាត់ដែរ បានជាខ្លួនទៅយកគាត់នៅម៉ោង ៤ ជិតភ្លឺ ព្រោះឈ្មោះ [redacted] ចិន្តា ជាអ្នកឲ្យខ្លួនមកយកគាត់ទៅផ្ទះ។ ផ្ទះសំណាក់ឈ្មោះបុរីថ្មី ឈ្មោះ [redacted] ចិន្តា ជាអ្នកបង់លុយ ចំពោះតម្លៃខ្លួនមិនបានដឹងប៉ុន្មានទេ។ ខ្លួនមានទំនាក់ទំនងជាសង្សានឹងគ្នាពីមុនមកជាសង្សាជាមួយគាត់មានរយៈពេលជាងមួយឆ្នាំមុនថ្ងៃកើតហេតុ ខ្លួនស្គាល់គាត់តាមរយៈបងស្រីគាត់ ខ្លួនធ្លាប់ទៅផ្ទះជួបឪពុកម្ដាយគាត់។ ពីមុនខ្លួននឹងឈ្មោះ [redacted] ចិន្តា ធ្លាប់ជិះម៉ូតូជាមួយគ្នា និងដើរញាំអីជាមួយគ្នា ប៉ុន្តែមិនបានស៊ីជម្រៅជាងនេះទេ។ចម្លើយដែលខ្លួនបានឆ្លើយនៅសាលាដំបូង ខ្លួនមិនបានចាំទេ។ បានជាគាត់ប្ដឹងខ្លួនព្រោះខ្លួនមិនបានចូលស្ដីដណ្ដឹងគាត់ ពីមុនខ្លួនធ្លាប់សន្យាថាចូលស្ដីដណ្ដឹងគាត់។ ខ្លួនសុំឲ្យសាលាឧទ្ធរណ៍ជួយរកយុត្តិធម៌ឲ្យខ្លួនតាមច្បាប់។

-លោក [redacted] វាសនា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា រឿងនេះបើពិនិត្យឲ្យបានជាក់លាក់ឃើញថា ទី១.បទល្មើសជាបទឧក្រិដ្ឋ ហេតុអ្វីបានជាសាលាដំបូងខេត្តបាត់ដំបងមិនឃុំខ្លួនជនជាប់ចោទ ទី២. ថ្ងៃកើតហេតុនៅខែមេសា ឆ្នាំ២០១៦ ហើយប្ដឹងថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ ដូច្នេះបទល្មើសនេះនិយាយឲ្យចំ គឺមិនមែនជាបទល្មើសជាក់ស្ដែងទេ វារំលងជាងមួយឆ្នាំ ហើយនៅពេលមកដល់អយ្យការខេត្តបាត់ដំបង ខាងស្រីបានប្ដឹងនៅស្នងការម្ដងរួចហើយ តែមិនមែនជាបទល្មើសជាក់ស្ដែង ប៉ុន្តែខាងស្រីដាក់ពាក្យបណ្ដឹងមកអយ្យការក៏ទៅជារឿងជាក់ស្ដែងទៅ ដូចដែលកូនក្ដីខ្លួនបានអះអាងថាជាសង្សាវាជារឿងពិតប្រាកដហើយ អញ្ចឹងនៅក្នុងរឿងនេះមានតែសាមីខ្លួនទេដែលដឹងច្បាស់ថាតាំងពីទំនាក់ទំនងគ្នាមករួមភេទជាមួយគ្នាប៉ុន្មានដងចាប់តាំងពីមុនកើតហេតុ និងនៅថ្ងៃកើតហេតុ ឬក្រោយថ្ងៃកើតហេតុនោះ។ ក្រោយពេលដែលសាកសួរមានលេចតម្រុយមួយថា ពួកគាត់ទាំងពីរធ្លាប់រួមភេទជាមួយគ្នាក្រោយថ្ងៃកើតហេតុនេះបើតាមគំនិតខ្លួនគឺថា ស្រីប្រកាន់ ប្រុសប្រកែក ហេតុផលខាងស្រីអត់បានកូនក្ដីខ្លួនជាប្ដី ហើយក៏បានប្ដឹងយកម៉ាឈ្មះម៉ាចាញ់ ហើយកស្ដុតាងគាត់ដាក់ស្បែក្រោយដាក់ពាក្យបណ្ដឹង ហើយក៏មិនបានធ្វើកោសល្យវិច័យលើទឹកកាមដែរ ហើយនៅក្នុងរឿងនេះខាងស្រីថារំលោភ ហើយខាងប្រុសថាមិនបានរំលោភ គឺព្រមព្រៀងរៀងៗខ្លួន ដូច្នេះនៅក្នុងរឿងនេះអត់មានធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់មកលើកូនក្ដីខ្លួនទេ អត់ជាក់ស្ដែង អត់ពិតប្រាកដ ទាំងពីភស្តុតាង ទាំងពីពេលវេលា ហើយការដាក់ភស្តុតាងខាងស្រីក៏អត់ជាក់លាក់តាមផ្លូវច្បាប់ដែរ អញ្ចឹងបទល្មើសព្រហ្មទណ្ឌអាចចោទបានទាល់តែមានធាតុផ្សំគ្រប់គ្រាន់ទើបអាចចោទមកលើកូនក្ដីខ្លួនបាន ពីបទរំលោភសេពសន្ថវៈបាន ដូច្នេះស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឲ្យកូនក្ដីខ្លួនរួចខ្លួនពីបទចោទ ព្រោះអត់មានធាតុផ្សំនៃបទល្មើសទេ។

-តំណាងមហាអយ្យការ បានធ្វើសេចក្ដីសន្និដ្ឋាននាពេលសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ បានឲ្យដឹងថា តាមអំណានចម្លើយ របស់ជនរងគ្រោះថា ជនជាប់ចោទបានចាប់រំលោភនៅថ្ងៃកើតហេតុនោះ ហើយចម្លើយរបស់ជនជាប់ចោទដែលបានឆ្លើយនៅសាលាដំបូងខេត្តបាត់ដំបង គាត់ប្រាប់ថាបានរំលោភលើជនរងគ្រោះដែរ គឺតាមការព្រមព្រៀង ប៉ុន្តែនៅសាលាឧទ្ធរណ៍ជនជាប់ចោទបានឆ្លើយបដិសេធថាខ្លួនមិនបានចាប់រំលោភទៅលើជនរងគ្រោះទៅវិញ តំណាងអយ្យការយល់ឃើញថាសាលាដំបូងខេត្តបាត់ដំបងសម្រេចផ្ដន្ទា



Scanned with CamScanner

លើជនជាប់ចោទឈ្មោះ [redacted] វាសនា មានលក្ខណៈត្រឹមត្រូវហើយ ដូច្នេះស្នើសុំឲ្យក្រុមប្រឹក្សាពិនិត្យ និងសម្រេចតាមច្បាប់។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់ការកត់សម្គាល់របស់តំណាងមហាអយ្យការ

-ក្រោយពីបានពិនិត្យកស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១. បណ្តឹងឧទ្ធរណ៍លេខ ៤៨ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ របស់លោកមេធាវី [redacted] តារា ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ស្នា ប្តឹងឧទ្ធរណ៍នឹង សាលក្រមព្រហ្មទណ្ឌលេខ ៤១៦ "ឃ" ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទាំងមូលនៃ សេចក្តីសម្រេច ត្រូវបានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ភ្នំពេញ អាចទទួលជំនុំជម្រះជាសមត្ថកិច្ចបាន យោងតាមបញ្ញត្តិមាត្រា ៣៧៥ និងមាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. ផ្អែកតាមលទ្ធផលសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ និង ការពិនិត្យនូវភស្តុតាងជាឯកសារផ្សេងៗក្នុងសំណុំរឿងឃើញថា បើទោះបីជាជនជាប់ចោទឈ្មោះ [redacted] វាសនា បានព្យាយាមឆ្លើយបដិសេធថាមិនបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈលើជនរងគ្រោះឈ្មោះ [redacted] ចិន្តា យ៉ាងណាក្តី។ ជាក់ស្តែងបើតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] វាសនា ឆ្លើយនៅចំពោះមុខសវនាការសាលាឧទ្ធរណ៍ភ្នំពេញថា"...*ពេលដល់បន្ទប់ផ្ទះសំណាក់នោះខ្លួនមិនបានដេកនៅទីនោះជាមួយគាត់(ជនរងគ្រោះឈ្មោះ [redacted] ចិន្តា) ទេ ហើយក៏មិនបានចាប់រំលោភគាត់(ជនរងគ្រោះឈ្មោះ [redacted] ចិន្តា)ដែរហើយម៉ោង៤ ជិតភ្លឺខ្លួនក៏មកយកគាត់(ជនរងគ្រោះឈ្មោះ [redacted] ចិន្តា) ជូនទៅផ្ទះវិញ នៅពេលទៅយកគាត់ (ជនរងគ្រោះឈ្មោះ [redacted] ចិន្តា) ខ្លួនមិនបានចាប់រំលោភគាត់ដែរ...*"។ រីឯចម្លើយជនជាប់ចោទឈ្មោះ [redacted] វាសនា នាពេលសវនាការនៅសាលាដំបូងខេត្តបាត់ដំបងឆ្លើយថា "*...នៅថ្ងៃកើតហេតុជាការរួមភេទដោយការព្រមព្រៀងពុំមានការបង្ខំទេ...*"(ឯកសារលេខ៣៧/៤)។ ទន្ទឹមនឹងដែរ ចម្លើយជនជាប់ចោទឈ្មោះ [redacted] វាសនា នៅចៅក្រមស៊ើបសួរឆ្លើយថា "*...ពេលចូលដល់ក្នុងបន្ទប់សំណាក់ខ្ញុំបាទ នឹងឈ្មោះ [redacted] ចិន្តា បានរួមភេទជាមួយនាងដូចធម្មតា ដោយមិនមានការបង្ខិតបង្ខំទេ។ ដោយពេលនោះនាងបានដោះសំលៀកបំពាក់នាងខ្លួនឯង រីឯ ខ្ញុំបាទក៏បានដោះសំលៀកបំពាក់ខ្ញុំ ខ្លួនឯងដែរ...*" (ឯកសារលេខ១១/២)។ ផ្ទុយទៅវិញ តាមចម្លើយជនរងគ្រោះឈ្មោះ [redacted] ចិន្តា នៅអយ្យការបានឆ្លើយថា "*...ពេលចូលដល់បន្ទប់ផ្ទះសំណាក់ភ្លាមឈ្មោះ [redacted] វាសនា បានចាក់សោរ ហើយបានចាក់គន្លឹះទ្វារជាប់ រួចឈ្មោះ [redacted] វាសនា ក៏បានចាប់ខ្ទប់មាត់និងបានចាប់បោកនាងខ្ញុំទៅលើគ្រែ រួចក៏បានចាប់រំលោភនាងខ្ញុំរហូតបានសម្រេច ហើយគម្រាមខ្ញុំមិនឲ្យស្រែក បើខ្ញុំហ៊ានស្រែកផ្អើលគេ គាត់នឹងច្របាច់កសម្លាប់នាងខ្ញុំចោល*



Scanned with CamScanner

ភ្លាម។ ខណៈពេលដែលឈ្មោះ [redacted] វាសនា ចាប់រំលោភនាងខ្ញុំនោះ ខ្ញុំក៏បានព្យាយាមរើបំរាស់ដែរ តែមិនឈ្នះគាត់ណាមួយខ្ញុំខ្លាចគេសម្លាប់ខ្ញុំចោល ទើបខ្ញុំមិនហ៊ានស្រែកប្រាប់អ្នកណាទាំងអស់...." (ឯកសារលេខ៣)។ ខណៈចម្លើយឈ្មោះ [redacted] ចិន្តា នៅចៅក្រមស៊ើបសួរឆ្លើយថា "...បន្ទាប់ពីប្រតាយប្រតប់គ្នារួចហើយ ឈ្មោះ [redacted] វាសនា បានចាប់ដោះរ៉ូបនាងខ្ញុំ ពេលនោះនាងខ្ញុំអស់កម្លាំង មិនបានប្រតាយប្រតប់ទៀតទេ។ បន្ទាប់ពីបានដោះរ៉ូបរួចហើយ ឈ្មោះ [redacted] វាសនា បានមកដោះខោអាវក្នុងរបស់នាងខ្ញុំ ហើយបានធ្វើសកម្មភាពយកដៃច្របាច់ និងពៅដោះនាងខ្ញុំ និង បានយកប្រដាប់ភេទមកបញ្ចូលក្នុងប្រដាប់ភេទនាងខ្ញុំ..." (ឯកសារលេខ៨/៣)។ ក្រៅពីចម្លើយទាំងនេះរបស់ជនរងគ្រោះ ជនរងគ្រោះក៏បានដាក់ភស្តុតាងមួយចំនួនដែលរួមមានរ៉ូបជនរងគ្រោះ និងរូបថតជនរងគ្រោះ ជាអាទិ៍ ដែលពាក់ព័ន្ធក្នុងអង្គហេតុនេះដែរ (*ឯកសារលេខ២០, លេខ២២, និងលេខ២៣*)។ ហេតុផលទាំងអម្បាមាណនេះ សបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] វាសនា ពិតជាបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈដូចការចោទប្រកាន់ប្រាកដមែនគឺ មិនដូចការឆ្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] វាសនា ឡើយ។

៣. មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] វាសនា ភេទ ប្រុស អាយុ២២ ឆ្នាំ (អត្តសញ្ញាណក្នុងសំណុំរឿង) ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅចំណុចផ្ទះ សំណាក់ [redacted] មិអូរតោគាំ១ សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិតាម មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

៤. រឿងក្តីនេះ ក្រៅពីសម្អាងហេតុខាងលើនេះ ត្រូវបានសាលាដំបូងខេត្តបាត់ដំបង បានលើកយកសម្អាងហេតុមកបញ្ជាក់ត្រឹមត្រូវហើយ ហើយក៏ប្រហាក់ប្រហែលនឹងការយល់ឃើញរបស់សាលាឧទ្ធរណ៍ដែរ។ ហេតុដូចនេះ សាលាឧទ្ធរណ៍ភ្នំពេញ ឯកភាពដោយពុំចាំបាច់លើកយកសម្អាងហេតុស្រដៀងគ្នាដដែលនោះយកមកបញ្ជាក់សារជាថ្មីទៀតទេ។

៥. សាលក្រមព្រហ្មទណ្ឌលេខ ៤១៦ "ឃ" ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបង ដែលបានសម្រេចកន្លងមកនេះឃើញថា មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ គប្បីក្រុមប្រឹក្សាជំនុំជម្រះសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ពិចារណា និងសម្រេចតម្កល់ បើសូម្បីតែតំណាងមហាអយ្យការក៏បានកត់សម្គាល់ថា សាលាដំបូងខេត្តបាត់ដំបងបានសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] វាសនា មានលក្ខណៈត្រឹមត្រូវហើយ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៨ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ របស់លោកមេធាវី [redacted] តាំងការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ស្នា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២. តម្កល់ សាលក្រមព្រហ្មទណ្ឌលេខ ៤១៦ "ឃ" ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល។



Scanned with CamScanner

សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វាសនា កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន្តា និងប្រកាសជាសាធារណៈថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១។

ទុកសិទ្ធិប្តឹងទាស់ សាទុក្ខតាមកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] [redacted] | [redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

សា[illegible] ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner